ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ថ្ងៃ ព្រហស្បតិ៍ ៩ រោច ខែស្រាពណ៍ ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤*
*រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០២០*

# សេចក្តីជូនដំណឹងសម្រាប់សារព័ត៌មានស្តីពី ជំនួបពិភាក្សាការងាររវាងឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី អូន ព័ន្ធមុនីរ័ត្ន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយឯកឧត្តម Masahiro MIKAMI ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពជប៉ុន ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

នៅព្រឹកថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០២០, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានទទួលជួបពិភាក្សាការងារជាមួយឯកឧត្តម Masahiro MIKAMI ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា ពិភាក្សាអំពីកិច្ចសហប្រតិបត្តិការក្នុងបរិការណ៍ដែលពិភពលោកកំពុងជួបប្រទះនូវការរីករាលដាលនៃវីរុសកូវីដ-១៩ ក៏ដូចជាការិះរកមធ្យោបាយ និងវិធានការរួមគ្នាដើម្បីបង្កលក្ខណៈងាយស្រួលសម្រាប់ការធ្វើដំណើរចេញ-ចូលទៅវិញទៅមកនៃប្រទេសទាំងពីរ សម្រាប់ធុរជន និងប្រជាជនកម្ពុជា និងជប៉ុន ។

ក្នុងការទប់ស្កាត់ការរីករាលដាលនៃវីរុសកូវីដ-១៩, កម្ពុជាបានដាក់ចេញនូវវិធានការម៉ឺងម៉ាត់ ហ្មត់ចត់បំផុត ។ ឯកឧត្តមឯកអគ្គរាជទូតជប៉ុន បានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានចាត់វិធានការយ៉ាងល្អប្រសើរក្នុងការបង្ការ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ហើយបានសន្យាថា រដ្ឋាភិបាលជប៉ុន នឹងបន្តផ្តល់ជំនួយបច្ចេកទេស, ហិរញ្ញប្បទានឥតសំណងបន្ថែមសម្រាប់ជួយគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ និងស្តារសម្បទាសេដ្ឋកិច្ចឡើងវិញបន្ទាប់ពីជំងឺកូវីដ-១៩ ។

ជាមួយគ្នានេះ, ដើម្បីចូលរួមកាត់បន្ថយនូវផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់កិច្ចសហប្រតិបត្តិការស្ទើរគ្រប់វិស័យ រួមទាំង សេដ្ឋកិច្ច ពាណិជ្ជកម្ម ទេសចរណ៍ ព្រមទាំងដើម្បីត្រៀមស្តារ និងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ ក៏ដូចជា កាត់បន្ថយផលប៉ះពាល់ដល់សកម្មភាពសហប្រតិបត្តិការនានា, ភាគីទាំងពីរ បានពិភាក្សាស្វែងរកយន្តការ ឬកិច្ចសម្របសម្រួលជាពិសេសណាមួយ ដើម្បីបង្កលក្ខណៈងាយស្រួលសម្រាប់ការធ្វើដំណើរចេញ-ចូលទៅវិញទៅមកប្រទេសទាំងពីរ កម្ពុជា-ជប៉ុន សម្រាប់ធុរជន និងប្រជាជននៃប្រទេសទាំងពីរ ។ ក្នុងនោះ, មានការពិភាក្សាលើលក្ខខណ្ឌសម្រាប់ធុរជន និងប្រជាជនដែលមាន

លំនៅដ្ឋាន (Business Track and Residence Track) ដោយរៀបចំឲ្យមានជាច្រកចេញ-ចូលរហ័ស (Fast Lane) និងយន្តការបណ្ដោះអាសន្នសម្រាប់ការឆ្លងដែន និងស្នាក់នៅរបស់ធុរជន (Cross Border Business Travellers) រវាងកម្ពុជា-ជប៉ុន នៃប្រទេសទាំងពីរ ជាដើម ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងវាយតម្លៃខ្ពស់ ចំពោះរដ្ឋាភិបាលជប៉ុនដែលបានជ្រើសរើសកម្ពុជា ជាប្រទេសអាទិភាពមួយ ក្នុងការរៀបចំនូវយន្តការចេញ-ចូលរហ័ស សម្រាប់ប្រជាជននៃប្រទេសទាំងពីរ ក្នុងពេលវិបត្តិនៃជំងឺកូវីដ-១៩ នេះ ។